# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## កំណត់ហេតុ

## ស្តីពី

## កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ សិក្ខាសាលាខេត្តកំពង់ធំ និងខេត្តព្រះវិហារ

ឆ្នាំពីរពាន់ប្រាំពីរ ខែ កក្កដា ថ្ងៃទី ម្ភៃប្រាំពីរ វេលាម៉ោងប្រាំបី នៅខេត្តកំពង់ធំ មានរៀបចំសិក្ខាសាលាមួយ ក្រោមអធិបតីភាពរបស់ឯកឧត្តម **សំ សុខផល** ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដោយមានការចូលរួមពីសំណាក ឯកឧត្តម **ឈុន ឈន់** អភិបាលរងខេត្តកំពង់ធំ និងឯកឧត្តម **ព្រាប តាន់** អភិបាលខេត្តព្រះវិហារ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ឈុន ឈន់** អភិបាលរងខេត្តកំពង់ធំ បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតី គណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៅតាមមន្ទីរជំនាញផ្សេងៗ ជុំវិញខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលាព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងធ្វើបទបង្ហាញជូនដល់មន្ត្រីរាជការនៃអង្គភាពជំនាញផ្សេងៗរបស់ខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានបញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការ ជូនមន្ត្រីរាជការក្នុងខេត្ត ខណៈដែលរាជរដ្ឋាភិបាលកំពុងតែធ្វើដំណើរឆ្ពោះទៅមុខប្រកបដោយឆន្ទៈដ៏មោះមុត ជាមួយនឹងកម្មវិធីនយោបាយកំណែទម្រង់រដ្ឋ ដែលជាសមាសធាតុគន្លឹះនៃអភិបាលកិច្ចល្អស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទីពីរនៃរដ្ឋសភា។

ជាបន្ទាប់ ឯកឧត្តម **ព្រាប តាន់** អភិបាលខេត្តព្រះវិហារ បានឡើងថ្លែងសន្ទរកថាចាប់អារម្មណ៍ក៏ដូចជាការលើកឡើងអំពីសារៈសំខាន់នៃសិក្ខាសាលាផ្សព្វផ្សាយ កម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចែករំលែកនូវបទពិសោធន៍ ក៏ដូចជាការបំពេញបន្ថែមនូវចំណេះដឹងទាំងឡាយ ដែលពាក់ព័ន្ធនឹងកំណែទម្រង់

ច្បាប់ និងតុលាការនេះ។ ច្បាប់គឺជាមាគ៌ាមួយដ៏សំខាន់ក្នុងចំណោមមាគ៌ាទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីអោយប្រទេសមានការគោរពច្បាប់ និងអនុវត្តច្បាប់មានប្រសិទ្ធិភាពស្របតាមនីតិរដ្ឋ ដើម្បីឱ្យប្រទេសយើងមានលក្ខណៈជានីតិរដ្ឋពិតប្រាកដ ដូច្នេះបុគ្គលម្នាក់ៗត្រូវតែចេះច្បាប់ យល់ដឹងអំពីច្បាប់ គោរពច្បាប់ និងអនុវត្តច្បាប់អោយបានខ្ជាប់ខ្ជួន ជាពិសេសមន្ត្រីរាជការទាំងស៊ីវិល ទាំងកងកម្លាំងប្រដាប់អាវុធ។

ឯកឧត្តមបានថ្លែងសង្កត់ធ្ងន់ថា សិក្ខាសាលានេះជាឱកាសដ៏កម្រមួយ ដែលយើងទាំងអស់គ្នាត្រូវចាំបាច់ក្រេបជញ្ជក់ឱ្យបាននូវខ្លឹមសាររបស់ច្បាប់ដើម្បីយកទៅអនុវត្ត។

ឯកឧត្តម **សំ សុខផល** បានធ្វើបទអន្តរាគមន៍ ជម្រាបជូនអង្គសិក្ខាសាលាអំពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទីបីនៃរដ្ឋសភា ដែលមានកំណែទម្រង់បួនជាស្នូលមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងទ័ព កំណែទម្រង់ច្បាប់ និងតុលាការ និងការប្រឆាំងអំពើពុករលួយ ក្នុងគោលដៅរួមមួយ គឺអភិបាលកិច្ចល្អ។

ឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាទាំងមូលអំពីដំណើរការនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ២០០០មក។ ចាប់ពីពេលនោះមកក្រុមការងារមួយត្រូវបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ ហើយនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ យុទ្ធសាស្ត្រនៃកំណែទម្រង់ច្បាប់ និងតុលាការនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ។

កម្មវិធីសកម្មភាពនេះចែកចេញជាបីផ្នែក ៖

- សកម្មភាពរយៈពេលខ្លី
- សកម្មភាពរយៈពេលមធ្យម និង
- សកម្មភាពរយៈពេលវែង។

បន្ទាប់ពីបទអន្តរាគមន៍របស់ឯកឧត្តមប្រធាន លោក **តូច សាឿន** ប្រធានតុលាការខេត្តកំពង់ធំ បានមានប្រសាសន៍លើកឡើងអំពីវិស័យច្បាប់ ដែលមានការចន្លោះប្រហោងក្នុងដំណើរការយុត្តាធិការនៃអតីតរដ្ឋកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតកម្ពុជាកន្លងមក ដូចជាក្រឹត្យច្បាប់លេខ២៧ អតីតរដ្ឋកម្ពុជា ដែលមានលក្ខណៈចន្លោះប្រហោង ហើយការដាក់ទណ្ឌកម្ម មិនមានលក្ខណៈគ្រប់គ្រាន់ ដោយការកំណត់បទល្មើសមានតិចតួច។ បន្តមកគឺសម័យអ៊ុនតាក់ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មានបី ឬបួន ច្បាប់នៅក្នុងនោះ មានទាំងច្បាប់ព្រហ្មទណ្ឌ មានទាំងនីតិវិធីព្រហ្មទណ្ឌ ហើយមានទាំងច្បាប់ចាត់តាំងតុលាការផងដែរ ដូច្នេះហើយទើបមានការស្មុគស្មាញច្រើន។

លោកបានលើកឡើងអំពីការរីកចំរើនក៏ដូចការវិវត្តនៃវិស័យច្បាប់ និងតុលាការ ដោយរាជរដ្ឋាភិបាលរៀបចំបង្កើតឱ្យមានក្រមធំចំនួនបួន មាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ លោកប្រៀបធៀបក្រមរដ្ឋប្បវេណីថ្មី និងចាស់ថា ក្រមរដ្ឋប្បវេណីថ្មីច្បាស់លាស់ជាងពីមុន។ ចំពោះស្ថានភាពបច្ចុប្បន្ននៅតុលាការខេត្តកំពង់ធំ លោកបានជម្រាបថា ចៅក្រមមាន០៥នាក់ ព្រះរាជអាជ្ញាមាន០២នាក់ និងក្រឡាបញ្ជី០២នាក់

ដែរ។ ទាក់ទិននឹងផ្នែកធនធានមនុស្សកន្លងមកមានទទួលការបណ្តុះបណ្តាលពីខាងអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែរហូតមកដល់ពេលឥឡូវចៅក្រមព្រះរាជអាជ្ញាត្រូវបានប្តូរវេនគ្នា ដើម្បីធ្វើការបណ្តុះបណ្តាលបន្តនៅសាលារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដើម្បីបង្កើនសមត្ថភាពក្នុងចំណាត់ការក្នុងការអនុវត្តច្បាប់នេះ ហើយក្រឡាបញ្ជីក៏ដូច្នោះដែរ មានវគ្គវិក្រឹត្យការក្រឡាបញ្ជីនៅក្របខណ្ឌតុលាការនេះ។ ជាបន្ទាប់ លោកបានជម្រាបជូនអង្គប្រជុំថា នៅតុលាការខេត្តកំពង់ធំសំណុំរឿងក្តីព្រហ្មទណ្ឌមានពី ៥០០ដល់៧០០រឿងក្នុងមួយឆ្នាំ ចំណែករឿងក្តីរដ្ឋប្បវេណីបើគិតជាមធ្យមមានសំណុំរឿងចាប់ពី ២០០ ដល់៣០០រឿងក្នុងមួយឆ្នាំ។ លោកបានបញ្ជាក់ថា បើពិនិត្យតាមសំណុំរឿងឃើញថា ចំនួនចៅក្រមមិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយចំពោះដំណើរការយុត្តាធិការរបស់តុលាការវិញ តែងជួបនូវបញ្ហាធនធានមនុស្ស និងបញ្ហាថវិកាដែលមានការខ្វះខាត។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ ហើយត្រូវតែបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធី ដើម្បីជួយដល់តុលាការផងដែរ។

លោក **រឹុច ទ៉ាន់អេន** ប្រធានតុលាការខេត្តព្រះវិហារ បានចាប់អារម្មណ៍ជម្រាបជូនអង្គសិក្ខាសាលាអំពីស្ថានភាពរបស់តុលាការខេត្តព្រះវិហារថា មានបុគ្គលិកសរុបចំនួន០៦នាក់ គឺចៅក្រមមាន ចំនួន០២នាក់ ព្រះរាជអាជ្ញាចំនួន០១នាក់ នឹងក្រឡាបញ្ជីមានចំនួន០៣នាក់ នៅក្នុងនោះមានផ្នែកគណនេយ្យម្នាក់ ការងារព្រហ្មទណ្ឌម្នាក់ និងម្នាក់ទៀតផ្នែកការងាររដ្ឋប្បវេណី។ រីឯសំណុំរឿងក្តីក្នុងមួយឆ្នាំមានជាង១០០សំណុំរឿង ដោះស្រាយបានតែ៦០សំណុំរឿងតែប៉ុណ្ណោះ ក្រៅពីនោះគឺនៅសល់ ហើយបញ្ហាប្រឈមមុខមាន ៖

- បញ្ហាចៅក្រម ព្រះរាជអាជ្ញា និងសមាជិកមានចំនួនតិច មិនអាចដោះស្រាយរឿងក្តីបានទាន់ពេល
- បញ្ហាវិស័យធនធានមនុស្សរបស់នគរបាលយុត្តិធម៌ ដែលទាក់ទិននឹងវិស័យច្បាប់
- មន្ត្រីនគរបាលយុត្តិធម៌ ធ្វើសំណុំរឿងបញ្ជូនមកតុលាការតែម្តងមិនបាច់មានអ្នកប្តឹងក្នុងករណីបទល្មើស
- លោកបានលើកឡើងពីការកែទម្រង់មិនទាន់ស៊ីជម្រៅទេ ព្រោះមិនទាន់មានការផ្សព្វផ្សាយទៅដល់មូលដ្ឋាន
- ទាក់ទិននឹងរឿងអាជ្ញាសាលា ទៅថ្ងៃអនាគត គឺមានបញ្ហាចំពោះអ្នករត់សំបុត្រ ដីកាកោះ និងបញ្ហាផ្សេងៗទៀត ពីព្រោះនៅចុងកាត់មាត់ញកគ្មានអ្នកណាហ៊ានទៅម្នាក់ឯងនោះទេ។
- បញ្ហាអាគារឈើបាក់ទ្រុឌទ្រោម និយាយពីលិចធ្លាយដល់កើត មិនអាចនិយាយរឿងលាក់ការបានទេ ចំណែកកន្លែងស្បថស្បែក៏បាក់ទ្រុឌទ្រោមដែរ បច្ចុប្បន្ននេះកំពុងចាំថវិកាពីក្រសួងធ្លាក់មក ហើយត្រូវរង់ចាំគោលការណ៍ពីក្រសួង ព្រោះគេមានគំរូសាងសង់ឱ្យដូចគ្នានឹងតុលាការផ្សេងៗទូទាំងប្រទេស បើខេត្តធំត្រូវធ្វើពីរជាន់ បើខេត្តតូចត្រូវធ្វើតែមួយជាន់។
- ចំពោះបញ្ហាធនធានមនុស្សកាលណាក្រឡាបញ្ជីណាម្នាក់ត្រូវទៅធ្វើវគ្គបណ្តុះបណ្តាល ហើយបើចំក្រឡាបញ្ជីនោះកាន់សំណុំរឿងរដ្ឋប្បវេណី ដូច្នេះសំណុំរឿងនោះត្រូវតែគរទុកចោលហើយ។
- សំណូមពរសូមបន្ថែមចៅក្រមចំនួន០៣នាក់ ក្នុងនោះព្រះរាជអាជ្ញារងម្នាក់ ហើយចំពោះចៅក្រម០២នាក់ទៀតនោះ សម្រាប់ជំនុំជំរះក្តីតាមក្រមរដ្ឋប្បវេណីថ្មី។ ករណីទឹកប្រាក់ចាប់ពី៥លានឡើងទៅ គឺត្រូវរៀបចំកាត់ក្តីជាក្រុមប្រឹក្សា។

ឯកឧត្តម **ប៉ែន ប៊ុនឈា** នាយករងអង្គភាពគ្រប់គ្រងគម្រោងបានធ្វើការបង្ហាញ ពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានលើកឡើងពីរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៍ ក.ក.ច.ន.យ) ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម **ឌិត មុន្ទី** ប្រធានតុលាការកំពូល សហប្រធាន (ក.ក.ច.ន.យ)បន្ទាប់មក ឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីអង្គភាពនៅក្រោមឱវាទរបស់ក្រុមប្រឹក្សា ៖

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍(អ.ស.ស)ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៍។
- អង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ) ដែលបានបង្កើតឡើងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ។

ជាបន្ទាប់ឯកឧត្តមបានធ្វើការបង្ហាញអំពីកម្មវិធីសកម្មភាពដែលមានក្នុង ឯកសារសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលមានចែកជូនជាឯកសារស្រាប់ដល់អង្គសិក្ខាសាលានាពេលនោះ ព្រមទាំងធ្វើការពន្យល់ផែនការសកម្មភាពនីមួយៗ និងបានដកស្រង់យកចំណុចសំខាន់ៗខ្លះ នៃឯកសារមកធ្វើអត្ថាធិប្បាយជូនអង្គសិក្ខាសាលាដូចជា បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់មានចែងក្នុងកម្មវិធីសកម្មភាពដូចជា បញ្ហាទប់ស្កាត់អំពើពុករលួយក្នុងតុលាការ និងការកកស្ទះសំណុំរឿងនៅក្នុងតុលាការ ដែលជាលទ្ធផលឧទាហរណ៍ដូចជានៅតុលាការក្រុងភ្នំពេញបានដោះស្រាយរួចជាស្ថាពរនោះមាន ៖

- បញ្ហាខ្វះបន្ទប់សវនាការ
- បញ្ហាខ្វះមេធាវី
- បញ្ហាដឹកជញ្ជូនជនជាប់ចោទពីពន្ធនាគារចូលសវនាការ
- ការបង្វិលដីកាកោះ ជាដើម។ល។

ចំណែកបញ្ហាផ្សេងៗទៀត ដែលអង្គប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៍បានសម្រេចដូចជា ៖

១-**កង្វះខាតចៅក្រម និងព្រះរាជអាជ្ញា** ៖ ជ្រើសរើសសិស្សចៅក្រមក្នុងមួយឆ្នាំអោយបានច្រើន ជាអតិបរមាតាមលទ្ធភាពសាលាភូមិន្ទចៅក្រមអាចធ្វើទៅបាន ។ ចំពោះគ្រូបង្រៀនសិស្សចៅក្រមនេះ មិនចាំបាច់គិតពីគោលការណ៍ថា ទាល់តែជាចៅក្រមទើបអាចជាគ្រូបង្រៀនបាននោះទេ ត្រូវរកសាស្ត្រាចារ្យជំនាញបង្រៀនទ្រឹស្តី រួចយកចៅក្រមក្នុងការងារជាអ្នកអនុវត្តមកបង្រៀនបន្ថែម ព្រមទាំងគួរមានគ្រូបង្រៀនប្រចាំសាលាភូមិន្ទចៅក្រមផងដែរ។

២-**ការបណ្តុះបណ្តាលចៅក្រមសម្រាប់វិវាទពាណិជ្ជកម្ម** ៖ ជាបឋមជ្រើសរើសចៅក្រម១២នាក់ពីចៅក្រមវិជ្ជាជីវៈសព្វថ្ងៃ។

៣-**ការបណ្តុះបណ្តាលក្រឡាបញ្ជី** ៖ ស្នើអោយក្រសួងយុត្តិធម៍ ជ្រើសរើសក្រឡាបញ្ជីមកធ្វើការបណ្តុះបណ្តាល ហើយត្រូវគិតពីគុណភាពជាធំ។

៤-**ការបណ្តុះបណ្តាលអាជ្ញាសាលា** ៖ ត្រូវរៀបចំក្របខណ្ឌច្បាប់មួយជាព្រះរាជក្រឹត្យ ឬអនុក្រឹត្យសិន ដើម្បីធ្វើ ការជ្រើសរើសអាជ្ញាសាលា មកធ្វើការបណ្តុះបណ្តាលសម្រាប់រយៈពេលពី ៦ខែ ទៅ១ឆ្នាំ និងអោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សហការជាមួយក្រសួងយុត្តិធម៌រៀបចំច្បាប់ជាមូលដ្ឋាន បណ្តើរៗ។

៥-**លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា** ៖ ត្រូវជម្រុញលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាចេញឱ្យបានឆាប់។

៦-**ការបោះពុម្ពសេចក្តីសម្រេចតុលាការ** ៖ ស្នើអោយរកការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើការសិក្សាលើ សេចក្តីសម្រេចរបស់តុលាការទាញជាយុត្តិសាស្ត្រ និងស្វាគមន៍ចំពោះការសម្រេចចិត្តរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលយកសាលក្រមស្ថាពរនៃតុលាការខេត្ត ក្រុងទៅបោះពុម្ពផ្សាយដោយខ្លួនឯងវិញ។

៧-**តុលាការគំរូ** ៖ ជម្រុញការអនុវត្តគម្រោងតុលាការគំរូ ព្រមទាំងដកស្រង់បទពិសោធន៍ល្អៗ និងចំណុច សំខាន់ៗនៃអង្គប្រជុំជំនុំជំរះវិសាមញ្ញកាត់ក្តីខ្មែរក្រហម ដែលមានលក្ខណៈស្តង់ដារអន្តរជាតិមកដាក់បញ្ចូល ធ្វើជាតុលាការគំរូ។

៨-**យន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ** ៖ គិតគូររៀបចំអោយបានឆាប់នូវយន្តការមួយសមស្របក្នុង ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

ជាបន្ទាប់ ចូលមកដល់របៀបវារៈសំណួរចម្លើយ និងការផ្តល់យោបល់ ឬសំណូមពរផ្សេងៗរបស់អង្គសិក្ខា-សាលាទាំងមូល ។

លោកអនុប្រធានមន្ទីរនគរូបនីយកម្មរៀបចំដែនដី និងសំណង់ បានលើកឡើងពីបញ្ហាដែលលោកតែងតែជួបការ លំបាកក្នុងដំណើរការទាក់ទងទៅនឹងលិខិតទទួលមរត៍ ឬលិខិតបដិញ្ញានទទួលមរតក៏ នៅពេលដែលប្តី ឬប្រពន្ធណាស្លាប់ ហើយអ្នកនៅរស់ ហើយពាក់ព័ន្ធនឹងរឿងទ្រព្យសម្បត្តិរួម ដូចជាដីធ្លីដែលត្រូវការលក់ ហើយនីតិវិធីគណៈកម្មាការ សុរិយោដីសូមឱ្យតុលាការជួយបញ្ជាក់ទៅលើករណីរនេះត្រង់ថា កូនដែលត្រូវទទួលមរតក៏ ជួនកាលកូននោះវិកលចរិត ឬកូនខ្លះជាប់ពន្ធនាគារ ហេតុនេះហើយសូមឱ្យធ្វើលិខិតបដិញ្ញានទទួលមរតក៏ និងសំណូមពរឱ្យតុលាការធ្វើលិខិតទទួល មរតក៏ផង។

បញ្ហាមួយទៀតពាក់ពន្ធ័នឹងគណៈកម្មាការសុរិយោដី និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្ទៃដីដែលយើង បានស៊ើបអង្កេតឃើញថា មិនមានប័ណ្ណកម្មសិទ្ធិទេ ប៉ុន្តែយោងតាមប្រកាសរួមលេខ០២ ពីក្រសួងនគរូបនីយកម្មដែនដី និងសំណង់ គឺពាក់ព័ន្ធនឹងបណ្តាំមរតក៏ ឬជាប់ពាក់ព័ន្ធនឹងកិច្ចសន្យា ក្នុងបញ្ហានេះគណៈកម្មាការសុរិយោដីមានទម្រង់ បែបបទមួយ គឺទម្រង់បែបបទនៃការចោទ គឺសាមីខ្លួនអាចដាក់ពាក្យបណ្តឹងទៅតុលាការ ឬអាចធ្វើពាក្យបណ្តឹងទៅ គណៈកម្មការសុរិយោដីបន្តទៀតរហូតដល់ថ្នាក់ជាតិ ថ្នាក់ខេត្ត ឬថ្នាក់ស្រុក ប៉ុន្តែបើលោកពិនត្យទៅឃើញថា រឿងនោះ ស្របលោកអាចដាក់ទៅតុលាការតែម្តង។

ឯកឧត្តម **សំ សុខផល** បានលើកឡើង និងធ្វើការពន្យល់បញ្ហាធំៗពីរ ដែលឯកឧត្តមបានមានប្រសាសន៍ថា បញ្ហានេះទាក់ទងទៅនឹងបច្ចេកទេសយ៉ាងច្រើន មានបច្ចេកទេសច្បាប់ ឬលិខិតបទដ្ឋានបច្ចេកទេសផ្សេងៗ ហើយមានភាពស្មុគស្មាញពិបាកក្នុងការពន្យល់បកស្រាយ។ ហេតុដូច្នេះហើយទើបឯកឧត្តមជំរុញឱ្យភ្នាក់ងារអ្នកអនុវត្តច្បាប់(សមត្ថកិច្ចរបស់ខេត្ត) ធ្វើការសហការគ្នា។ ស្ថាប័នជំនាញផ្សេងៗគួរជួបជុំគ្នារកដំណោះស្រាយ ព្រោះថា បើឯកឧត្តមធ្វើការបកស្រាយវាពិបាកយល់ ព្រោះជាការងារបច្ចេកទេសសុទ្ធសាធ។ បញ្ហាមួយទៀតដែលទាក់ទងនឹងបញ្ហាសុរិយោដី ឯកឧត្តមបានលើកឡើងថា គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខេត្ត រហូតដល់ថ្នាក់កណ្តាលនេះជាយន្តការ ហើយក៏អាចមានការលំបាកនៅពេលខ្លះដែរ។ ឯកឧត្តមបានបញ្ជាក់ទៀតថា បើសិនជាយើងមានសហប្រតិបត្តិការតាមមន្ទីរផ្សេងៗ ប្រាកដជាដំណើរការបានល្អ ហើយអាចដោះស្រាយបញ្ហាបាន។

លោកអភិបាលស្រុករវៀងខេត្តព្រះវិហារ បានសំណូមពរថា សូមឱ្យក្រសួងយុត្តិធម៌ បង្កើនចំនួនចៅក្រមនៅតាមតុលាការខេត្តឱ្យបានច្រើន ដើម្បីដោះស្រាយរាល់សំណុំរឿងក្នុងមួយឆ្នាំៗ ដោយលោកបានលើកឡើងថា សំណុំរឿងនេះចេះតែកើនច្រើនឡើងៗ ហើយដោះស្រាយមិនទាន់បានដូច្នេះ ជាហេតុធ្វើឱ្យជនល្មើសចេះតែបានចិត្ត កាន់តែកើនឡើងដែរ។ ដូចជាកន្លងមកលោកធ្លាប់បានធ្វើការសហការចាប់បទល្មើសព្រៃឈើមួយចំនួននៅក្នុងឆ្នាំ ២០០២ ២០០៣ ហើយបច្ចុប្បន្នលោកបានសួរទៅរដ្ឋបាលព្រៃឈើ ហើយខាងរដ្ឋបាលព្រៃឈើឆ្លើយថា បានបញ្ជូនសំណុំរឿងទៅតុលាការហើយ ។ មកដល់ពេលនេះតុលាការនៅមិនទាន់ដោះស្រាយអ្វីទាំងអស់ សំណុំរឿងកកស្ទះលើតុ។ ហេតុដូចនេះលោកសុំស្នើឱ្យក្រសួងយុត្តិធម៌ បញ្ជូនបុគ្គលិកឱ្យបានគ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការដោះស្រាយឱ្យបានគ្រប់សំណុំរឿងទាំងអស់ ជាពិសេសបទល្មើសព្រៃឈើនេះជាដើម។

លោក **គង់ ណារិន** នាយករដ្ឋបាលព្រៃឈើ កំពង់ធំ លោកបានលើកឡើងនៅស្លាយទី១៦នៃឯកសារដែលបានចែកជូនទាក់ទិនទៅនឹងការ «ដោះស្រាយបញ្ហាសំណុំរឿងចាស់ៗ» ដែលទុកចោលហើយមិនបានចាត់ការ ដោយបានសួរជាសំណួរថា តើដោះស្រាយបញ្ហាសំណុំរឿងបានទាំងស្រុងហើយឬនៅ? ហើយបើនៅសេសសល់តើមកពីមូលហេតុអ្វី?

ឯកឧត្តម **សំ សុខផល** បានជម្រាបជូនពីបញ្ហាកកស្ទះសំណុំរឿងថា ដោយមូលហេតុខ្វះចៅក្រម បុគ្គលមន្ត្រីតុលាការ បញ្ហាខ្វះអាគារសវនាការ មធ្យោបាយដឹកជញ្ជូនផ្សេងៗ ឬក៏បញ្ហាថវិកាជាដើម។ល។ ដូច្នេះហើយតុលាការខេត្តក្រុងគួរធ្វើរបាយការណ៍ផ្ញើជូនទៅឧត្តមក្រុមប្រឹក្សាអង្គចៅក្រម។

លោក **គីម វ៉ាស៊ី** អភិបាលស្រុកសន្ទុក ខេត្តកំពង់ធំ សំណួររបស់លោក គឺទាក់ទងទៅនឹងគណៈកម្មការសុរិយោដី និងការវាស់វែងដីធ្លី ដែលផ្តល់បណ្ណ័កម្មសិទ្ធស្របច្បាប់ជូនទៅប្រជាពលរដ្ឋ។ ជាមួយគ្នានេះ លោកបានលើកយកបញ្ហាមួយក្នុងការចូលរួមដោះស្រាយដីមួយកន្លែង ដោយមានការចូលរួមពីសំណាក់អភិបាលខេត្ត និងអភិបាលស្រុក។

ភាគីទាំងពីរបានចូលរួមដោះស្រាយជាមួយគណៈកម្មការសុរិយោដីមានថ្នាក់ខេត្ត ថ្នាក់ស្រុក និងមន្ទីរពាក់ព័ន្ធដទៃទៀត ដែលបានចូលរួមដោះស្រាយ និងសម្របសម្រួលក្រៅប្រព័ន្ធតុលាការ។

ដំណោះស្រាយគឺភាគីទាំងពីរបានឯកភាពគ្នា ដោយមានការសម្របសម្រួលពីអភិបាលខេត្ត ស្រុក និងគណៈកម្មការសុរិយោដីធ្វើការវាស់វែង ដោយមានលិខិតស្នាមផ្សេងៗ ដែលយល់ព្រមធ្វើការសម្រុះសម្រួលគ្នាហើយ។ ប៉ុន្តែក្រោយមកមានភាគីម្ខាងទៀតបានដាក់ពាក្យបណ្ដឹងទៅតុលាការត្រង់ចំណុចនេះ លោកក៏បានសួរថា តើគណៈកម្មការសុរិយោដីអាចផ្ដើមការវាស់វែង និងធ្វើប័ណ្ណជូនពួកគាត់បានដែរឬទេ នៅពេលភាគីទាំងពីរបានឯកភាពគ្នា?

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា ទាក់ទិននឹងបញ្ហាសុរិយោដីនេះ ឯកឧត្តមមានសិទ្ធិ ឬសម្រេចក្នុងលក្ខណៈស្របច្បាប់ត្រឹមត្រូវប៉ុណ្ណោះ។ ចំពោះបញ្ហាដីធ្លីដែលមានទំនាស់មានបញ្ហាត្រូវឡើងតុលាការ ឯកឧត្តមបានស្នើឱ្យពិនិត្យមើលអនុក្រឹត្យនោះដើម្បីឱ្យដឹងថា មានសិទ្ធិ ឬក៏អត់សិទ្ធិ ហើយឯកឧត្តមបានបញ្ជាក់ថា បញ្ហាគណៈកម្មការសុរិយោដីមានសិទ្ធិត្រឹមការសម្របសម្រួលប៉ុណ្ណោះ ចំណែករឿងធ្វើប័ណ្ណកម្មសិទ្ធិគឺ ក្រសួងជំនាញជាអ្នកធ្វើ។

លោក **ទូច សារឿន** ប្រធានតុលាការខេត្តកំពង់ធំ លោកបានលើកឡើងអំពីបញ្ហាកកស្ទះសំណុំរឿងនៅតុលាការ ដែលមានសព្វថ្ងៃនេះ លោកបានជម្រាបជូនអង្គប្រជុំថា ស្នើសុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានវិធីរិះរកមធ្យោបាយ ដើម្បីដោះស្រាយបញ្ហាកកស្ទះសំណុំរឿងនៅតុលាការ។ ក្នុងពេលនោះដែរ លោកបានលើកឧទាហរណ៍នៃរឿងក្ដីព្រហ្មទណ្ឌជាដើម ដែលតុលាការបានកាត់ក្ដីកំបាំងមុខ លុះដល់ពេលកាត់ក្ដីកំបាំងមុខហើយជនល្មើសបានរត់គេចខ្លួនទៅធ្វើការនៅបរទេស(មានស្រុកថៃជាដើម)។ រហូតដល់បួន ឬដប់ឆ្នាំទើបគាត់វិលមកវិញ ឯរឿងក្ដី នោះវាផុតកំណត់អាជ្ញាយុកាលទៅហើយដែរ។ លោកបានសួរថា តើមានមូលដ្ឋានណាដែលអាចជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការគ្រប់ខេត្តក្រុង?

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា យោងទៅតាមការលើកឡើងពីបញ្ហាកកស្ទះសំណុំរឿងគ្រប់ខេត្តទាំងអស់នោះ ឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាថា ពេលឯកឧត្តមត្រឡប់ទៅវិញ នឹងញុំាំនាំបញ្ហាទាំងនោះជូនថ្នាក់ដឹកនាំដើម្បីដោះស្រាយ និងស្រង់យកគំនិតយោបល់ល្អៗរបស់អង្គសិក្ខាសាលាទាំងមូលទៅធ្វើការពិចារណាក្នុងការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការឱ្យបានកាន់តែប្រសើរឡើង។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

នាយករងអង្គភាពគ្រប់គ្រងគម្រោង

អ្នកធ្វើរបាយការណ៍

ប៉ែន ប៊ុនណា

សេង វ៉ាន់ដា ស៊ុន សិរីវុធ